ហ៊ុន សែន បានចំណេញអ្វី និង ខាតអ្វី ?

រ្ចាមាន ហ៊ុន សែន នៅអង្គការសហប្រជាជាតិ តើគាត់បានចំណេញអ្វី និង ខាតអ្វី ?

មានមតិ ជនខ្មែរខ្លះ យល់ឃើញថា ហ៊ុន សែន បានចំណេញច្រើន នៅលើផ្ទៃនយោបាយក្នុងស្រុក ព្រោះគាត់អាចបង្ហាញដល់ប្រជាពលរដ្ឋខ្មែរថា របបគាត់ត្រូវបាន អ.ស.ប. ទទួលស្គាល់ ហើយ ការទទួលស្គាល់អន្តរជាតិនេះឯង អាចធ្វើគាត់ពោលអះអាង ចំពោះប្រជាពលរដ្ឋខ្មែរថា គាត់ ជានាយករដ្ឋមន្ត្រីស្របច្បាប់។ ការយល់ឃើញនេះ ជាប្រក្យត្រភាព ឈរលើតក្កសាស្ត្រ (logique) នៃរូបភាព ដែលគ្មាននរណាអាចប្រកែកបាន។ រូបភាពពិតនេះ ហ៊ុន សែន យកវាមកប្រើ មិនមែនសំរាប់ធ្វើអោយសូប់នៅក្នុងសង្គម តែសំរាប់បង្ហើន នូវសេចក្ដីខ្លាច ព្រោះធាតុ អំណាច នៃរបបគាត់ជា របបអត្តាវសិក។ នៅក្នុងរបបបែបនេះ ប្រជាពលរដ្ឋ គ្មានមានអ្វីសំរាប់ការពារសិទ្ធិរបស់ខ្លួននោះឡើយ ព្រោះអាជ្ញាធរ ស្ថិតនៅក្នុងសភាពប្រាជ្ញាអាប់ នៃអំណាចផ្តាច់ការ នាំអោយជនទាំងឡាយ គ្មានច្បាប់ការពារ រស់នៅ ក្នុងសេចក្ដីខ្លាច នៃអំណាច ព្រោះ របបអត្តាវសិក តម្រូវអោយប្រជាពលរដ្ឋ គោរពហួសប្រមាណ នូវអំណាចរបស់ខ្លួន។ នៅក្នុងឆន្ទៈនេះ អ្នកផ្តាច់ការ ទុកប្រជាពលរដ្ឋ ជា

ហ៊ុន សែន បានចំណេញអ្វី និង ខាតអ្វី ?

សត្វលោក (créature) ទន់ខ្សោយ ដែលត្រូវតែគោរពដាច់ខាត អ្នកដឹកនាំ ដែលជាសត្វលោកខ្លាំងដោយអំណាច។ នៅក្នុងកំនិតនេះឯង ដែល ហ៊ុន សែន ថ្លែងថា អ្នកខ្សោយ ត្រូវតែចាញ់ រីឯអ្នកខ្លាំងត្រូវតែឈ្នះ។ កំនិតបែបនេះ គឺឈរលើ ការបែងភាគមនុស្ស ជាសត្វ មានតែ សការគតិ ស្តាប់បង្គាប់ ទណ្ឌកិច្ច។ នៅក្នុងស្មារតីបែបហ្នឹង ហើយវាត្រឹមតែប៉ុណ្ណឹង ពោលថា ហ៊ុន សែន ទទួលបានចំណេញ ក្នុងឋានៈជាសត្វតិរច្ឆាន។

តែជនខ្មែរខ្លះទៀត យល់ឃើញថា វត្តមាន ហ៊ុន សែន វានាំអោយគាត់ខាតជ្រើនក្រៃនោះដែរនៅលើផ្នែ នៃតម្លៃមនុស្ស របស់គាត់ផ្ទាល់។ ដូចយ៉ាង នីយ នៃសេចក្ដីថ្លែងការណ៍ របស់គាត់ បង្ហាញអោយឃើញថា គាត់គ្មានការអៀនខ្មាស់អ្វីបន្ដិចសោះឡើយ ដោយប្រើការភ្ជួតកុហក សំរាប់ការពារ អំពើប្លន់អំណាច របស់គាត់ ព្រោះគាត់គ្មានអ្វីក្រៅពីយកកំនិតថោកទាបនេះ មកប្រើតែប៉ុណ្ណោះ ដ្បិតគាត់រស់នៅក្នុងអកុសល ជាចីរកាល ហើយ អកុសល វាពុំអាចលើកតម្លៃមនុស្សបាននោះទេ។

ដូច្នេះ ការចំណេញ និង ខាត របស់ ហ៊ុន សែន វាជាដំបៅចេញរដី របស់គាត់ ដែលគេមើលឃើញ និង ធុំក្លិន ពីចម្ងាយ។ រេទិកានៃ អ.ស.ប. វាពុំអាច ជាទីកន្លែង សំរាប់គាត់មកលាងដំបៅស្អុយ របស់គាត់បាននោះឡើយ។ ក្រប់ករណី ហ៊ុន សែន និងបន របស់គាត់ ជាលក្ខណៈ នៃប្រជាជាតិខ្មែរ។